ក្រុមសៀវភៅការរុករកឃើញ®

# ហេតុអ្វីព្រះជាម្ចាស់ មិនឆ្លើយតបការអធិស្ឋានរបស់ខ្ញុំ?



Why God doesn't answer me?

នាំមកជូនដោយ
នំម៉ាណាប្រចាំថ្ងៃ

ការស្វែងយល់ស៊ីជម្រៅ




## ហេតុអ្វីព្រះជាម្ចាស់មិនឆ្លើយតបការអធិស្ឋានរបស់ខ្ញុំ?

តើអ្នកបានសន្ទនាជាមួយព្រះជាម្ចាស់ ជាទៀងទាត់ទេ? តើអ្នកបានទូលថ្វាយបញ្ហារបស់អ្នក ហើយទូលសូមជំនួយពីទ្រង់ឬទេ? មនុស្សជាច្រើននៅមិនទាន់យល់ អំពីរឿងនេះ។ បើអ្នកបានទូលសូមអ្វីមួយ ពីព្រះ ហើយមិនបានទទួលការឆ្លើយតបពីទ្រង់ នោះអ្នកប្រហែលជាចង់ឈប់ជឿថា ព្រះពិតជាមានមែន ឬអ្នកជឿថា បើទ្រង់ពិតជាមានមែន នោះទ្រង់ក៏មិនសូវខ្វល់ពីអ្នកដែរ។

អ្នកប្រហែលជាមានការភ្ញាក់ផ្អើល ពេលដែលអ្នកបានដឹងថា ព្រះគម្ពីរបានចែង អំពីការអធិស្ឋានរបស់មនុស្សជាច្រើន ដែលធ្លាប់ឆ្លងកាត់បញ្ហានេះ។ បទគម្ពីរទំនុកដំកើងជំពូក ៧៧ គឺជាសេចក្តីអធិស្ឋាន ដែលលោកអេសាភបានសរសេរ។ នៅក្នុងសេចក្តីអធិស្ឋាននេះ យើងឃើញថា លោកអេសាភស្ទើរតែគ្មានសង្ឃឹមនៅក្នុងខ្លួនទាល់តែសោះ ព្រោះព្រះទ្រង់ហាក់ដូចជាមិនអើពើរចំពោះគាត់។ ប៉ុន្តែ នៅចុងបញ្ចប់នៃសេចក្តីអធិស្ឋាននេះ លោកអេសាភក៏បានងាកចេញពីភាពអស់សង្ឃឹម ហើយបែរមករកការទុកចិត្តព្រះកាន់តែខ្លាំង។ តើគាត់អាចមានក្តីសង្ឃឹមឡើងវិញ ដោយរបៀបណា? ត្រង់ចំណុចនេះ យើងចាំបាច់ត្រូវយកសេចក្តីអធិស្ឋានមួយជំពូកនេះ មកធ្វើការសិក្សា ដូចតទៅ :



ទំនុកដំកើង ៧៧:១-១២

*១ ខ្ញុំបន្លឺសំឡេង អំពាវនាវដល់ព្រះ*
*ខ្ញុំបន្លឺសំឡេងឡើងដល់ព្រះ ហើយទ្រង់ក៏ស្តាប់ខ្ញុំ*
*២ នៅថ្ងៃដែលខ្ញុំមានសេចក្តីវេទនា នោះខ្ញុំបានស្វែងរកព្រះអម្ចាស់*
*នៅពេលយប់ នោះខ្ញុំបានប្រទូលដៃឡើងឥតឈប់ឈរ*
*ព្រលឹងខ្ញុំមិនព្រមក្សាន្តទុក្ខទេ*
*៣ ខ្ញុំនឹកពីព្រះ នោះខ្ញុំមានចិត្តទុរន់ទុរា ខ្ញុំនឹកជញ្ជឹង*
*នោះវិញ្ញាណខ្ញុំក៏ល្វើយទៅ។ –បង្អង់*
*៤ ◎ ទ្រង់ទល់ភ្នែកទូលបង្គំមិនឲ្យលក់ទូលបង្គំមាន*
*សេចក្តីទុក្ខប្រដេញ ទាល់តែរកនិយាយមិនចេញ*
*៥ ទូលបង្គំបានពិចារណាពីអស់ទាំងថ្ងៃកន្លងទៅហើយ*
*និងអស់ទាំងឆ្នាំពីកាលមុន*
*៦ ទូលបង្គំនឹកឃើញទំនុកដែលធ្លាប់ច្រៀងនៅពេលយប់*
*នោះទូលបង្គំបានត្រិះរិះក្នុងចិត្ត ហើយវិញ្ញាណទូលបង្គំ*
*ក៏ស្វែងរកសេចក្តីចំឡើយដែរ*
*៧ តើព្រះអម្ចាស់ទ្រង់នឹងបោះបង់ចោលជាដរាបឬ*
*តើទ្រង់មិនព្រមប្រោសប្រាណទៀតទេឬ*
*៨ តើសេចក្តីសប្បុរសនៃទ្រង់អស់រលីងជាដរាបទៅឬ*
*តើសេចក្តីសន្យាទ្រង់អាក់ខានទៅជានិច្ចឬ*
*៩ តើព្រះទ្រង់ភ្លេចប្រព្រឹត្តដោយករុណារបស់ទ្រង់ហើយឬ*
*តើទ្រង់បានបិទបាំងសេចក្តីអាណិតមេត្តារបស់ទ្រង់ទុក*

*ដោយសេចក្ដីខ្វាល់ដែរឬអី។ –បង្អង់*
*១០ ១ នោះទូលបង្គំបាននឹកថា នេះហើយជាសេចក្ដីទុក្ខ*
*របស់ទូលបង្គំ តែទូលបង្គំនឹងនឹកចាំពីគ្រា*
*ដែលព្រះហស្តស្តាំនៃព្រះដ៏ខ្ពស់បំផុត បានប្រោសវិញ*
*១១ ទូលបង្គំនឹងរឭកពីអស់ទាំងការនៃព្រះយេហូវ៉ា ដ្បិតទូលបង្គំនឹកឃើញ*
*អស់ទាំងការអស្ចារ្យ ដែលទ្រង់បានធ្វើកាលពីដើម*
*១២ ទូលបង្គំនឹងរំពឹងគិតពីគ្រប់ទាំងការរបស់ទ្រង់ ហើយពិចារណា*
*ពីកិច្ចដែលទ្រង់ធ្វើទាំងប៉ុន្មាន។*
*—ទំនុកដំកើង ៧៧:១-១២*

លោកអេសាភបានចាប់ផ្ដើមការអធិស្ឋានរបស់គាត់ ដោយស្រែករកព្រះ ក្នុងពេលដែលគាត់ត្រូវការជំនួយពីទ្រង់។ មនុស្សជាច្រើនក៏បានអធិស្ឋានដូចនេះដែរ។ គាត់បានចូលមករកព្រះ ដោយ "សេចក្ដីវេទនា" ហើយព្រលឹងគាត់ "មិនព្រមក្សាន្តទុក្ខ"ទេ(ខ.២) ប្រហែលជាមកពីគាត់ចង់ឲ្យព្រះទ្រង់ចូលមកក្នុងបញ្ហារបស់គាត់ ហើយកែប្រែស្ថានភាពរបស់គាត់។ យើងមិនដឹងថា គាត់មានបញ្ហាអ្វីទេ។ ប៉ុន្តែ យើងអាចនិយាយថា កាលនោះ លោកអេសាភកំពុងតែស្រេកឃ្លានជំនួយរបស់ព្រះជាម្ចាស់។ មនុស្សម្នាក់ៗសុទ្ធតែឆ្លងកាត់ពេលវេលា និងស្ថានភាពដ៏ពិបាក។ គ្មាននរណាម្នាក់ ដែលរស់នៅដោយគ្មានការឈឺចាប់សោះនោះឡើយ។ ប៉ុន្តែ

---

*"ទូលបង្គំនឹងរឭកពី* ***អស់ទាំងការនៃព្រះយេហូវ៉ា*** *ដ្បិតទូលបង្គំនឹកឃើញ****អស់ទាំងការអស្ចារ្យ*** *ដែលទ្រង់បានធ្វើកាលពីដើម។*
*ទំនុកដំកើង ៧៧:១១*

---

ពេលដែលយើងចូលទៅរកព្រះជាម្ចាស់ ពេលដែលយើងមានបញ្ហា ដូចលោកអេសាភ តើយើងនឹងមានជំនួយមកពីព្រះ ឬយើងនឹងមានការភ័ន្តភាំងកាន់តែខ្លាំង? បញ្ហារបស់លោកអេសាភកាន់តែយ៉ាប់យ៉ឺន ហើយគាត់ក៏បានឆ្ងល់ថា តើព្រះទ្រង់បានភ្លេចរបៀបប្រព្រឹត្តចំពោះគាត់ ដូចសេចក្តីករុណា ឬសេចក្តីអាណឹតហើយឬ(ខ.៨-៩)។ ក្នុងពេលដែលព្រះជាម្ចាស់មានភាពស្ងាត់ស្ងៀម មិនឃើញឆ្លើយតបចំពោះគាត់ លោកអេសាភក៏បានគិតថា ការអធិស្ឋានមិនបាននាំឲ្យគាត់រកឃើញចម្លើយ ឬទំនុកចិត្តឡើងវិញឡើយ។



# គោលបំណងនៃការអធិស្ឋាន

វាជាការត្រឹមត្រូវណាស់ ដែលលោកអេសាកបានទូលសូមអ្វីមួយពីព្រះ ព្រោះបទគម្ពីរ១យ៉ូហាន ៥:១៤ បានលើកទឹកចិត្តយើងថា "យើងក៏មានសេចក្ដីក្លាហាន ដល់ទ្រង់យ៉ាងដូច្នេះដែរ គឺថា បើយើងនឹងសូមអ្វីដែលត្រូវតាមព្រះហឫទ័យទ្រង់ នោះទ្រង់នឹងទទួលព្រម"។ ព្រះយេស៊ូវបានពន្យល់ពួកសាវ័ករបស់ទ្រង់ថា "តាំងពីដើមមក អ្នករាល់គ្នាមិនបានសូមអ្វី ដោយនូវឈ្មោះខ្ញុំទេ ឥឡូវ ចូរសូមចុះ នោះអ្នករាល់គ្នានឹងបាន ដើម្បីឲ្យសេចក្ដីអំណររបស់អ្នករាល់គ្នាបានពោរពេញពិត"(យ៉ូហាន ១៦:២៤)។

ព្រះជាម្ចាស់សព្វព្រះទ័យឲ្យយើងនាំការទូលសូម និងតម្រូវការទាំងអស់ មកទូលថ្វាយដល់ទ្រង់។ តែយើងក៏ត្រូវអធិស្ឋាន ដោយសារមូលហេតុជាច្រើនទៀត គឺមិនគ្រាន់តែដោយសារយើងមានតម្រូវការ ឬមានអ្វីដែលត្រូវទូលសូមប៉ុណ្ណោះឡើយ។

លោកអេសាកប្រហែលជាគិតថា ការអធិស្ឋានតែម្យ៉ាង នឹងជួយដោះស្រាយបញ្ហារបស់គាត់។ តែពេលដែលព្រះទ្រង់ប្រាប់យើងឲ្យអធិស្ឋាន ទ្រង់មិនគ្រាន់តែចង់ឲ្យយើងទូលថ្វាយទ្រង់ អំពីបញ្ហានីមួយៗដែលយើងមានប៉ុណ្ណោះទេ ហើយទ្រង់ក៏មិនសព្វព្រះទ័យឲ្យយើងអធិស្ឋាន តាមក្បួន ឬទម្លាប់ ដូចអ្នកកាន់សាសនានោះឡើយ។ ព្រះទ្រង់សព្វព្រះទ័យឲ្យយើងនិយាយទៅកាន់ទ្រង់ (ការអធិស្ឋានជាការសន្ទនាជាមួយព្រះ) ហើយស្គាល់ទ្រង់កាន់តែច្បាស់ គឺដូចអ្វីដែលយើងធ្វើ

ព្រះអង្គសព្វព្រះទ័យឲ្យយើង**និយាយទៅកាន់ទ្រង់** ហើយ**ស្គាល់ទ្រង់កាន់តែច្បាស់** គឺដូចអ្វីដែលយើងធ្វើ**នៅក្នុងទំនាក់ទំនងដទៃទៀត។**

នៅក្នុងទំនាក់ទំនងដទៃទៀត។

ជាញឹកញាប់ យើងគិតថា ការអធិស្ឋាន គឺជារូបមន្តមួយ ដែលក្នុងនោះ ការទូលសូមជំនួយពីព្រះ នាំឲ្យយើងទទួលការឆ្លើយតបដ៏អស្ចារ្យពីទ្រង់ ដែលដោះស្រាយបញ្ហារបស់យើង។ លោកអេសាភក៏មានផ្នត់គំនិតដូចនេះផងដែរ បានជាគាត់សួរថា ហេតុអ្វី ព្រះជាម្ចាស់មិនឆ្លើយតបការអធិស្ឋានរបស់គាត់?(ទំនុកដំកើង ៧៧:៧-៩)។

យើងប្រហែលជាធ្លាប់សួរសំណួរដូចនេះផងដែរ។ បើសិនជាយើងគិតថា យើងអធិស្ឋាន គ្រាន់តែដើម្បីឲ្យបានទទួលអ្វីមួយ ដែលយើងត្រូវការ នោះយើងនឹងមានការខកចិត្តជាញឹកញាប់ ហើយឆ្ងល់ថា តើព្រះខ្វល់ពីយើងដែរឬទេ។ សូមយើងស្រមៃថា បើសិនជាព្រះទ្រង់គ្រាន់តែឆ្លើយតបចំពោះសេចក្តីអធិស្ឋាននីមួយៗ របស់មនុស្សទាំងអស់(តាមគំនិតរបស់យើង) ដោយប្រទានអ្វីៗដែលយើងរាល់គ្នាទូលសូម ឬត្រូវការ នោះពិភពលោកនឹងមានភាពវឹកវរភ្លាម។ ព្រោះអ្វីដែលយើងគិតថា យើងត្រូវការ និងចង់បាន អាចមានការប៉ះទង្គិច និងប្រឆាំងនឹងការអធិស្ឋានទូលសូមរបស់អ្នកដទៃ។

ទីបំផុត សំណួរ និងការសង្ស័យរបស់គាត់ ព្រមទាំងភាពស្ងាត់ស្ងៀមរបស់ព្រះ បាននាំឲ្យគាត់ធ្វើការសន្និដ្ឋានថា "តើព្រះទ្រង់ភ្លេចប្រព្រឹត្តដោយករុណារបស់ទ្រង់ហើយឬ?"(ខ.៩)។ ការសួរដូចនេះ គឺមិនខុសពីការនិយាយថា "ខ្ញុំបានអធិស្ឋានពេញមួយយប់។ តែព្រះជាម្ចាស់មិនបានធ្វើអ្វីសោះ។ ដូចនេះ ខ្ញុំសន្និដ្ឋានថា ខ្ញុំមិនអាចទុកចិត្តព្រះអង្គបានទេ។ ទ្រង់ភ្លេចទំនុកបម្រុងខ្ញុំហើយ។ ខ្ញុំមិនអាចពឹងផ្អែកលើទ្រង់ទេ"។

ការគិតដូចនេះ បាននាំឲ្យលោកអេសាភចង់ឈប់ពឹងផ្អែកលើព្រះទាំងស្រុងតែម្តង។ តើធ្វើដូចម្តេចឲ្យគាត់អាចពឹងផ្អែកលើព្រះអង្គ នៅពេលដែលគាត់មិនទុកចិត្តព្រះអង្គ?



# តើលោកអេសាភធ្វើដូចម្ដេច?

ភ្លាមៗនោះ លោកអេសាភស្រាប់តែត្រឡប់មករកសេចក្ដីពិតវិញ ដោយថ្លែងថា "ទូលបង្គំនឹងរឭកពីអស់ទាំងការនៃព្រះយេហូវ៉ា"(ខ.១១) ។ ការភ័យខ្លាច និងការសង្ស័យរបស់គាត់ ក៏ត្រូវបានជំនួស ដោយការទុកចិត្តព្រះឡើងវិញ។ ដូចនេះ តើមានរឿងអ្វីកំពុងតែកើតឡើង?

សូមយើងកុំយល់ច្រឡំ។ ការសង្ស័យរបស់លោកអេសាភ មិនបានរលាយបាត់ភ្លាមៗទាំងស្រុងឡើយ។ គាត់គ្រាន់តែបានទទួល ឬឃើញពន្លឺនៃសេចក្ដីពិតខាងវិញ្ញាណ ភ្លឺឡើងក្នុងគំនិតគាត់ប៉ុណ្ណោះ។ គាត់បានធ្វើនូវការដ៏សាមញ្ញ តែសំខាន់ណាស់។ គាត់បានងាកចេញពីការផ្ដោតទៅលើខ្លួនឯង មកផ្ដោតទៅលើព្រះជាម្ចាស់វិញ។ គាត់ឈប់និយាយទៅកាន់ព្រះអំពីបញ្ហារបស់គាត់ទៀតហើយ ប៉ុន្តែ ពេលនេះ គាត់អធិស្ឋានទៅកាន់ព្រះជាម្ចាស់ ដោយនិយាយអំពីព្រះអង្គវិញ បានសេចក្ដីថា គាត់កំពុងតែរំឭកខ្លួនឯង ដោយនិយាយថា ព្រះទ្រង់ជានរណា ហើយទ្រង់បានធ្វើការអ្វីខ្លះ (ទាំងនៅក្នុងជីវិតគាត់ផ្ទាល់ ក៏ដូចជានៅក្នុងទំព័រព្រះគម្ពីរ)។

យើងមិនចាំបាច់ត្រូវមានការភ័យខ្លាច ចំពោះការសង្ស័យរបស់យើងទេ ហើយយើងក៏មិនចាំបាច់ត្រូវលាក់បាំងការសង្ស័យរបស់យើង នៅចំពោះព្រះដែរ។ ព្រះទ្រង់ជ្រាបអំពីការសង្ស័យ និងភាពអសុវត្ថិភាពរបស់យើង។ ប៉ុន្តែ ពេលណាយើងមានបញ្ហា ទ្រង់សព្វព្រះទ័យឲ្យយើង ផ្ដោតទៅលើទ្រង់ ជាជាងផ្ដោតទៅលើភាពកម្សោយរបស់យើង។

ការសង្ស័យរបស់លោកអេសាភបានបណ្ដាលឲ្យគាត់មានការអស់ស

ង្សឹម។ ប៉ុន្តែ ពេលដែលគាត់គិតអំពីព្រះ ហើយចំណាយពេលនឹកចាំថា ព្រះទ្រង់ជានរណា ហើយមើលសេចក្ដីអ្វីដែលព្រះគម្ពីរបានចែងអំពីទ្រង់ គាត់ក៏បានទទួលការលើកទឹកចិត្ត និងមានភាពស្រស់ស្រាយឡើង។

តាមធម្មតា យើងយកការអធិស្ឋាន ជាជម្រើសចុងក្រោយ ពេលណាយើងមានបញ្ហា។ ហើយពេលយើងអធិស្ឋាន យើងច្រើនតែអធិស្ឋានដូចលោកអេសាភ ហើយទូលដល់ព្រះ នូវបញ្ហាដែលយើងត្រូវការឲ្យទ្រង់ដោះស្រាយឲ្យយើង។ ផ្ទុយទៅវិញ យើងត្រូវយល់អំពីគោលបំណងនៃការអធិស្ឋានដូចលោកអេសាភ នៅក្នុងខ.១១។ ការអធិស្ឋានគឺជាការសន្ទនាជាមួយព្រះ ដែលក្នុងនោះ យើងត្រូវរៀនស្គាល់ទ្រង់ឲ្យកាន់តែច្បាស់។ វាជាពេលដែលយើងអាចមានទំនុកចិត្តកាន់តែខ្លាំងចំពោះព្រះ ខណៈពេលដែលយើងនឹកចាំ អំពីការអ្វីដែលទ្រង់បានធ្វើសម្រាប់យើង និងការអ្វីដែលទ្រង់នឹងធ្វើសម្រាប់យើង ហើយការអ្វីដែលទ្រង់បានសន្យាថា នឹងធ្វើសម្រាប់យើង ព្រមទាំងនឹកចាំថា ទ្រង់បានបង្កើតយើងឲ្យក្លាយជានរណា។ និយាយរួម យើងត្រូវតែផ្ដោតទាំងស្រុងទៅលើទ្រង់។

បើយើងចាប់ផ្ដើមការអធិស្ឋាន ដោយផ្ដោតទៅលើខ្លួនឯង និងទៅលើបញ្ហារបស់យើង នោះមានន័យថា យើងរឹតត្បិតការអធិស្ឋានរបស់យើង ហើយយើងមើលឃើញតែខ្លួនឯង។ បើការអធិស្ឋានរបស់យើងផ្ដោតទៅលើព្រះ នោះពេលណាយើងចូលដល់ចំណុចដែលនិយាយអំពីបញ្ហារបស់យើង យើងក៏លែងផ្ដោតទៅលើខ្លួនឯងទៀត។ ការនេះមិនមានន័យថា បញ្ហារបស់យើងនឹងរលាយបាត់ ឬត្រូវបានដោះស្រាយភ្លាមៗនោះទេ។

ប៉ុន្តែ វាមានន័យថា យើងអាចប្រឈមមុខដោះស្រាយវា ព្រោះយើងពឹងផ្អែកទៅលើព្រះ មិនមែនពឹងផ្អែកលើខ្លួនឯងទៀតទេ។ ហេតុអ្វីព្រះជាម្ចាស់មិនឆ្លើយតប? ជាញឹកញាប់ យើងមិនដឹងច្បាស់ថា ហេតុអ្វីព្រះជា

ម្ចាស់ហាក់ដូចជាមានភាពស្ងាត់ស្ងៀមនោះឡើយ។ ទោះជាយ៉ាងណាក៏ដោយ អ្វីដែលយើងអាចរៀនបានពីរឿងរបស់លោកអេសាភនោះគឺ ភាពស្ងាត់ស្ងៀមរបស់ព្រះបាននាំឲ្យលោកអេសាភមានពេល ដើម្បីផ្លាស់ប្ដូរការគិតរបស់គាត់ ដោយងាកចេញពីការផ្ដោតទៅលើខ្លួនឯង ហើយបែរមកផ្ដោតទៅលើព្រះអង្គវិញ។ ការស្ងាត់ស្ងៀមរបស់ព្រះ បានធ្វើឲ្យគាត់ឈឺចាប់ តែវាបានជួយគាត់ឲ្យចូលទៅជិតព្រះអង្គកាន់តែខ្លាំង ដែលនោះការសំខាន់បំផុត ដែលព្រះអង្គសព្វព្រះទ័យឲ្យយើងធ្វើ។ ទ្រង់សព្វព្រះទ័យឲ្យយើងស្គាល់ទ្រង់ ហើយមានភាពស្និទ្ធស្នាលជាមួយទ្រង់។ បើព្រះទ្រង់តែងតែប្រទាននូវដំណោះស្រាយភ្លាមៗ សម្រាប់បញ្ហារបស់យើង តើយើងនឹងខំរៀនឲ្យស្គាល់ទ្រង់ឬទេ? យើងនឹងមិនចំណាយពេលច្រើនជាមួយទ្រង់ទេ។ យើងនឹងចាត់ទុកទ្រង់ ដូចមាស៊ីនដោះស្រាយបញ្ហាស្វ័យប្រវត្តិ។

# ទំនុកដំកើង ៧៧:១៣-២០

១៣ ឱព្រះអង្គអើយ ផ្លូវទ្រង់ជាផ្លូវបរិសុទ្ធ
តើមានព្រះឯណាដែលធំដូចជាទ្រង់
១៤ ទ្រង់ជាព្រះដែលធ្វើការយ៉ាងអស្ចារ្យ
ទ្រង់បានសំដែងឲ្យស្គាល់ឥទ្ធានុភាពនៃទ្រង់
នៅកណ្ដាលអស់ទាំងសាសន៍
១៥ ទ្រង់បានប្រោសបណ្ដារាស្ត្រឲ្យរួច
ដោយព្រះហស្តរបស់ទ្រង់
គឺជាពួកកូនចៅយ៉ាកុប និងយ៉ូសែបផង។ –បង្អង់
១៦ ◎ ឱព្រះអង្គអើយ ទឹកទាំងប៉ុន្មានបានឃើញទ្រង់
គឺទឹកទាំងប៉ុន្មានបានឃើញទ្រង់ ហើយមានសេចក្ដីភិតភ័យ
អស់ទាំងទីជំរៅក៏ញ័រដែរ

១៧ អស់ទាំងពពកបានចាក់ទឹកចេញ
ផ្ទៃមេឃក៏បញ្ចេញសូររំពង
ហើយព្រួញរបស់ទ្រង់បានហើរទៅគ្រប់អន្លើដែរ
១៨ សូរសៀងនៃផ្គររបស់ទ្រង់ក៏នៅក្នុងខ្យល់កួច
ផ្លេកបន្ទោរបានបំភ្លឺលោកីយ៍ ឯផែនដីក៏ញ័រកក្រើក
១៩ ផ្លូវដែលទ្រង់យាង នោះនៅក្នុងសមុទ្រ
ហើយផ្លូវច្រករបស់ទ្រង់ ក៏នៅទីមានទឹកច្រើន
ឥតមានអ្នកណាឃើញដានព្រះបាទទ្រង់ឡើយ
២០ ទ្រង់បាននាំរាស្ត្រទ្រង់ ដូចជាហ្វូងចៀម
គឺដោយដៃរបស់ម៉ូសេ និងអើរ៉ុន។

**ពេលដែលលោកអេសាភផ្លាស់**ប្តូរទស្សនៈរបស់គាត់ ហើយចាប់ផ្តើមនិយាយអំពីព្រះ នៅក្នុងការអធិស្ឋានរបស់គាត់ តើគាត់បានជញ្ជឹងគិតអំពីអ្វី?

**ការប្រោសលោះរបស់ព្រះ:** លោកអេសាភបាននឹកចាំអំពីរបៀបដែលព្រះបាន "ប្រោសលោះ"(ខ.១៥) រាស្ត្ររបស់ទ្រង់ កាលពីមុន។ ការលោះអ្វីមួយ គឺជាការបង់ថ្លៃ ដើម្បីយកវាមកវិញ។ ដូចនេះ ក្នុងបទគម្ពីរនេះ លោកអេសាភកំពុងតែនឹកចាំអំពីពេលដែលព្រះជាម្ចាស់បានជួយសង្គ្រោះរាស្ត្រទ្រង់ ឲ្យរួចពីបញ្ហា ឬខ្មាំងសត្រូវរបស់ពួកគេ ហើយនាំពួកគេមករកទ្រង់វិញ ដោយសុវត្ថិភាព។

គ្រីស្ទបរិស័ទក៏អាចនឹកចាំ អំពីរបៀបដែលព្រះបានប្រោសលោះពួកគេឲ្យរួចពីជីវិត ដែលបានដាច់ចេញពីទ្រង់ ហើយសមនឹងទទួលការជំនុំជម្រះ។ ព្រះយេស៊ូវដែលជាព្រះរាជបុត្រានៃព្រះ យាងចុះមកផែនដី ដើម្បី

បង់ថ្លៃលោះមនុស្ស ដែលបានបដិសេធព្រះ។ យើងរាល់គ្នាសុទ្ធតែបានរស់នៅ ដោយហាក់ដូចជាមិនខ្វល់ពីព្រះសោះ បានជាយើងចេះតែធ្វើអ្វីៗតាមចិត្តរបស់យើង។ នេះហើយជាអំពើបាប។

"ដ្បិតឯព្រះអង្គ(ព្រះយេស៊ូវ) ដែលមិនបានស្គាល់បាបសោះ នោះទ្រង់បានធ្វើឲ្យត្រឡប់ជាតួបាប ជំនួសយើងរាល់គ្នាវិញ ដើម្បីឲ្យយើងរាល់គ្នាបានត្រឡប់ទៅជាសេចក្ដីសុចរិតរបស់ព្រះ ដោយនូវព្រះអង្គនោះឯង"(២កូរិនថូស ៥:២១)។ ព្រះវរបិតាបានឲ្យព្រះយេស៊ូវដែលទ្រង់គ្មានបាបសោះ មកទទួលខុសត្រូវចំពោះអំពើបាបរបស់យើង ហើយទ្រង់ក៏បានទទួលទោសនៃអំពើបាបជំនួសយើង ដើម្បីឲ្យយើងអាចទទួលការប្រោសលោះ(ត្រឡប់មករកព្រះឡើងវិញ)។ ព្រះយេស៊ូវត្រូវគេឆ្កាង ដោយទ្រង់បានសុគតជំនួសយើង ហើយបន្ទាប់មកទ្រង់ក៏បានមានព្រះជន្មរស់ឡើងវិញ។ ព្រះយេស៊ូវបានអញ្ជើញមនុស្សម្នាក់ៗ ឲ្យចូលរួមជាមួយទ្រង់ នៅក្នុងជីវិតថ្មី ដែលរស់នៅជាមួយព្រះ។

ដែលការប្រោសលោះរបស់ព្រះ ជាចំណុចចាប់ផ្ដើមនៃការអធិស្ឋានរបស់លោកអេសាភជាយ៉ាងណា នោះវាក៏ជាចំណុចផ្ដោតដ៏សំខាន់ នៅក្នុងការសន្ទនារបស់យើងជាមួយព្រះផងដែរ។ ពេលណាយើងពោលថា "ទ្រង់បានប្រោសបណ្ដារាស្ត្រឲ្យរួច ដោយព្រះហស្តរបស់ទ្រង់"(ទំនុកដំកើង ៧៧:១៥) នោះយើងក៏គួរតែចាំថា យើងត្រូវពឹងផ្អែកទៅលើព្រះខ្លាំងប៉ុណ្ណា។ យើងមិនអាចធ្វើជាកម្មសិទ្ធិរបស់ទ្រង់បានទេ បើយើងនៅតែពឹងផ្អែកលើកម្លាំង ឬសមត្ថភាពរបស់យើងនោះ។ យើងធ្វើជាកម្មសិទ្ធិរបស់ទ្រង់ ដោយពឹងផ្អែកលើការអ្វីដែលព្រះយេស៊ូវបានធ្វើ និងដោយទុកចិត្តទ្រង់។ សរុបមក យើងត្រូវរស់នៅ ជារៀងរាល់ថ្ងៃ ហើយប្រឈមមុខនឹងទុក្ខលំបាកគ្រប់យ៉ាង ដោយពឹងផ្អែកលើព្រះ និងចូលទៅជិតទ្រង់។

**ភាពធំប្រសើររបស់ព្រះ :** ការនឹកចាំអំពីការជួយសង្គ្រោះរបស់ទ្រង់ គឺជាការផញ្ជឹងគិតអំពីភាពធំប្រសើរ អំណាច និងកម្លាំងរបស់ទ្រង់។ គ្រីស្ទបរិស័ទអាចផញ្ជឹងគិត អំពីការជាច្រើនដែលព្រះទ្រង់បានធ្វើក្នុងជីវិតពួកគេ។ ពួកគេក៏អាចបើកព្រះគម្ពីរ ដើម្បីស្វែងយល់អំពីព្រះជន្ម ការបង្រៀន និងព្រះរាជកិច្ចរបស់ព្រះយេស៊ូវ។ ទ្រង់ជា "សេចក្តីពោរពេញ" របស់ព្រះ(កូល៉ុស ១:១៥,១៩) ហើយយើងអាចអានសេចក្តីដែលបានចែងអំពីកម្លាំង និងសេចក្តីស្រឡាញ់ដ៏អស្ចារ្យរបស់ទ្រង់។

គ្មានការអ្វីដែលអាចឈ្នះព្រះយេស៊ូវ ឬពិបាកពេកសម្រាប់ទ្រង់ឡើយ។ តាមពិត ទ្រង់បានប្រាប់អ្នកដើរតាមទ្រង់ថា "នៅលោកីយ៍នេះ នោះអ្នករាល់គ្នាមានសេចក្តីវេទនាមែន ប៉ុន្តែ ត្រូវសង្ឃឹមឡើង ដ្បិតខ្ញុំបានឈ្នះលោកីយ៍ហើយ"(យ៉ូហាន ១៦:៣៣)។ អំណាច និងកម្លាំង ដែលធ្វើឲ្យយើងមានការភ័យខ្លាច ក៏ស្ថិតនៅក្រោមការបង្គាប់របស់ព្រះ។ ការអ្វីដែលអ្នកខ្លាច ក៏កំពុងតែខ្លាចទ្រង់ផងដែរ។

អ្នកប្រហែលជាចង់និយាយថា "ប៉ុន្តែ ព្រះយេស៊ូវត្រូវបានគេធ្វើគុត នៅលើឈើឆ្កាងហើយ! ដូចនេះ សេចក្តីស្លាប់បានឈ្នះទ្រង់ហើយតើ"។ ជាការពិតណាស់ ការសុគតរបស់ព្រះយេស៊ូវ គឺជាផែនការរបស់ព្រះ ដើម្បីជួយសង្គ្រោះយើងរាល់គ្នា។ ហើយជាងនេះទៅទៀត បីថ្ងៃបន្ទាប់ពីព្រះយេស៊ូវសុគត ទ្រង់បានយាងចេញពីផ្នូរ។ ព្រះយេស៊ូវបានឈ្នះខ្មាំងសត្រូវទាំងអស់ គឺសូម្បីតែសេចក្តីស្លាប់ក៏ដោយ។ ទោះយើងជួបបញ្ហាអ្វីក៏ដោយ ក៏យើងនៅតែអាចទុកចិត្តថា ព្រះទ្រង់នឹងនាំយើងឆ្លងកាត់បញ្ហាទាំងនោះ។

លោកអេសាភក៏បានពិចារណាអំពីធម្មជាតិ ដែលជាកម្មសិទ្ធិរបស់ព្រះផងដែរ។ គឺដូចដែលគាត់បានសរសេរថា "អស់ទាំងពពកបានចាក់ទឹក

ចេញ ផ្ទៃមេឃក៏បញ្ចេញសូររំពង ហើយព្រួញរបស់ទ្រង់បានហើរទៅគ្រប់អន្លើដែរ។ សូរសៀងនៃផ្គររបស់ទ្រង់ក៏នៅក្នុងខ្យល់កួច ផ្លេកបន្ទោរបានបំភ្លឺលោកីយ៍ ឯផែនដីក៏ញ័ររកក្រើក"(ទំនុកដំកើង ៧៧:១៧-១៨)។ ក្នុងលោកិយនេះ គ្មានអ្វីដែលធំជាងព្រះទៀយ។ ព្រះអង្គគ្រប់គ្រងលើអ្វីៗទាំងអស់។

ពេលដែលក្តីសង្ឃឹមកំពុងតែរលាយបាត់ ហើយយើងហាក់ដូចជាទាល់ច្រក យើងចាំបាច់ត្រូវទុកចិត្តលើព្រះ ហើយផ្តោតទៅលើទ្រង់។ ទ្រង់បានធ្វើនូវការគ្រប់យ៉ាងដែលទ្រង់ចាំបាច់ត្រូវធ្វើ ដើម្បីប្រោសលោះយើង ហើយទ្រង់មានអំណាចជាងបញ្ហារបស់យើង។ ទ្រង់ប្រហែលជាមិនឆ្លើយតបតាមរបៀប ឬតាមពេលវេលាដែលយើងរំពឹងចង់បាននោះទេ។ ប៉ុន្តែ យើងចាំបាច់ត្រូវទុកចិត្តថា ផែនការរបស់ទ្រង់ល្អឥតខ្ចោះ។ យើងមិនដឹងថាទ្រង់នឹងធ្វើការអ្វីខ្លះទេ តែយើងអាចទុកចិត្តថា ការអ្វីក៏ដោយដែលទ្រង់ធ្វើគឺសុទ្ធតែល្អបំផុតសម្រាប់យើង។

**បុគ្គលិកលក្ខណៈ និងអាកប្បកិរិយារបស់ព្រះ ចំពោះយើង** : សេចក្តីពិតចុងក្រោយ ដែលលោកអេសាភបានរកឃើញ ក្នុងការអធិស្ឋាននោះគឺ : ព្រះអម្ចាស់ជាអ្នកគង្វាលរាស្ត្ររបស់ទ្រង់។ គឺដូចដែលគាត់បានសរសេរថា "ទ្រង់បាននាំរាស្ត្រទ្រង់ ដូចជាហ្វូងចៀម គឺដោយដៃរបស់ម៉ូសេ និងអើរ៉ុន"(ទំនុកដំកើង ៧៧:២០)។ ត្រង់ចំណុចនេះ លោកអេសាភកំពុងតែនឹកចាំ អំពីពេលមួយ ដែលព្រះបានជួយសង្គ្រោះរាស្ត្រទ្រង់ ឲ្យរួចពីភាពជាទាសករ ក្នុងទឹកដីអេស៊ីព្ទ ដោយដឹកនាំពួកគេ "ដូចហ្វូងចៀម"។ ទ្រង់បានប្រើលោកម៉ូសេ និងអើរ៉ុន ឲ្យ "នាំ" រាស្ត្រទ្រង់ ចេញពីប្រទេសនោះ ហើយទីបំផុត ចូលទៅក្នុងទឹកដីមួយ ដែលទ្រង់បានញែកចេញសម្រាប់ពួកគេ។ សេចក្តីដែលចែងថា ព្រះជាអ្នកគង្វាលរបស់យើង គឺជាការប្រៀបធៀបដ៏

ល្អមួយ ដែលយើងត្រូវយកមកពិចារណា។ អ្នកគង្វាលតែងតែនៅជាប់ជាមួយចៀមរបស់ខ្លួនជានិច្ច ហើយតែងតែដឹងថា ចៀមរបស់គាត់ត្រូវការអ្វីព្រមទាំងផ្គត់ផ្គង់ពួកគេផង។ ហើយពេលណាគាត់ត្រូវដឹកនាំចៀមរបស់គាត់ កាត់តាមកន្លែងដែលមានគ្រោះថ្នាក់ គាត់ខិតខំការពារ មិនឲ្យចៀមណាមួយបាត់ឡើយ។ សត្វចៀមពឹងផ្អែកលើអ្នកគង្វាលរបស់ពួកវា ១០០%។

យើងក៏គួរតែមានការគិតដូចនេះ ចំពោះព្រះផងដែរ។ យើងជាចៀម ហើយទ្រង់ជាអ្នកគង្វាល។ សូម្បីតែនៅពេលដ៏ពិបាក យើងនៅតែអាចនិយាយថា "ព្រះអម្ចាស់ជាអ្នកគង្វាលខ្ញុំ ខ្ញុំមិនខ្វះអ្វីសោះ"(ទំនុកដំកើង ២៣:១)។ តើហេតុអ្វី? ព្រោះទ្រង់ខ្វល់ពីយើង ហើយនឹងមិនចាកចេញ ឬបោះបង់យើងចោលឡើយ(ហេព្រើរ ១៣:៥)។

ព្រះយេស៊ូវបានហៅព្រះអង្គទ្រង់ថា អ្នកគង្វាលល្អ។ ទ្រង់បានពន្យល់អំពីទំនាក់ទំនង ដែលទ្រង់មានជាមួយចៀមទ្រង់ យ៉ាងដូចនេះថា :

*"ឯខ្ញុំ ជាអ្នកគង្វាលល្អ ខ្ញុំស្គាល់ចៀមរបស់ខ្ញុំ ហើយចៀមក៏ស្គាល់ខ្ញុំ។ ដូចជាព្រះវរបិតាទ្រង់ស្គាល់ខ្ញុំ ហើយខ្ញុំក៏ស្គាល់ទ្រង់ដែរ ខ្ញុំស៊ូប្តូរជីវិតខ្ញុំនឹងចៀម។ ខ្ញុំក៏មានចៀមឯទៀត ដែលមិនទាន់នៅក្នុងក្រោលនេះនៅឡើយ ត្រូវតែខ្ញុំនាំចៀមទាំងនោះមកដែរ វានឹងស្តាប់តាមសំឡេងខ្ញុំ នោះនឹងមានហ្វូងតែ១ និងអ្នកគង្វាលតែ១វិញ។ ហេតុនោះបានជាព្រះវរបិតាទ្រង់ស្រឡាញ់ខ្ញុំ ពីព្រោះខ្ញុំដាក់ជីវិតខ្ញុំចុះ ដើម្បីឲ្យបានយកមកវិញ។ គ្មានអ្នកណាដកយកជីវិតពីខ្ញុំបានទេ គឺខ្ញុំដាក់ជីវិតចុះដោយខ្លួនខ្ញុំ ខ្ញុំអាចនឹងដាក់ជីវិតនេះចុះ ហើយក៏អាចនឹងយកមកវិញបានដែរ គឺខ្ញុំដាក់ជីវិតចុះដោយខ្លួនខ្ញុំ ខ្ញុំអាចនឹងដាក់ជីវិតនេះចុះ ហើយក៏អាចនឹងយកមកវិញបានដែរ ខ្ញុំបាន*

*ទទួលអំណាចនេះ ពីព្រះវរបិតាខ្ញុំមក"(យ៉ូហាន ១០:១៤-១៨)។*

ពេលណាយើងមានអារម្មណ៍ថា ព្រះកំពុងតែមានភាពស្ងៀមស្ងាត់ចំពោះការអធិស្ឋានរបស់យើង យើងចាំបាច់ត្រូវចាំថា ទ្រង់ជាអ្នកគង្វាលរបស់យើង។ យើងតែងតែស្ថិតនៅក្នុងការថែរក្សាការពាររបស់ទ្រង់ជានិច្ច។ ព្រះយេស៊ូវ ដែលជាអ្នកគង្វាលល្អរបស់យើង បានសុគតជួសយើង(យ៉ូហាន ១១:១៤) ហើយបានមានព្រះជន្មរស់ឡើងវិញ(ខ.១៨) ដើម្បីនាំយើងវិលត្រឡប់ទៅរកការប្រកបទាក់ទងជាមួយព្រះវិញ។ យើងជាកម្មសិទ្ធិរបស់ទ្រង់ ហើយទ្រង់នឹងមិនបោះបង់យើងចោលឡើយ ទោះយើងជួបការលំបាកយ៉ាងណាក៏ដោយ។

បើសិនជាអ្នកកំពុងតែមានការលំបាកនៅក្នុងការអធិស្ឋាន ឬមានបញ្ហាប្រឈមណាមួយ ហើយអ្នកគិតថា ព្រះមិនឆ្លើយតបការអធិស្ឋានរបស់អ្នក នោះសូមទៅប្រាប់អ្នកដឹកនាំពួកជំនុំរបស់អ្នក ឬគ្រីស្ទបរិស័ទណាម្នាក់ដែលអ្នកស្គាល់ និងទុកចិត្ត។ ពួកគេនឹងជួយលើកទឹកចិត្តអ្នក ហើយអធិស្ឋានជាមួយអ្នក។